**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**សាលាភូមិន្ទរដ្ឋបាល**

លេខ ៨៦៩ ស.ភ.រ

ថ្ងៃ ពុធ ៧ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៨

**សូមគោរពជូន**

**សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងប្រធានគ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** សំណើសុំការពិនិត្យនិងសម្រេចអនុញ្ញាតឲ្យបេក្ខជនកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីមធ្យម និងមន្ត្រីក្រមការនៃក្រសួង ស្ថាប័នសាមីនីមួយៗដើម្បីទទួលបានសិទ្ធិចូលសិក្សាក្នុងវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល ដោយដាក់កម្មសិក្សាការីនោះឲ្យស្ថិតក្នុងស្ថានភាពទំនេរពីមុខងារដោយរក្សាបៀវត្ស និងមុខតំណែងនៅដដែល។

**យោង ៖** សេចក្តីសម្រេចស្តីពីការទទួលស្គាល់បេក្ខជនកម្មសិក្សាការីវគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់និងវគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម ឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ ជាប្រធាន ក្រសួង ស្ថាប័នទាំងអស់ មេត្តាជ្រាបថា នៅឆ្នាំ២០១៨នេះ សាលាភូមិន្ទរដ្ឋបាលបានសម្រេចទទួលស្គាល់បេក្ខជនកម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីគ្រប់គ្រងរដ្ឋបាល មន្ត្រីមធ្យម និងមន្ត្រីក្រមការឆ្នាំ២០១៨ សរុបចំនួន៤០១រូបមកពីគ្រប់ក្រសួង ស្ថាប័នរបស់រដ្ឋ។ សាលានឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាលចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ អាស្រ័យហេតុនេះ ខ្ញុំសូមគោរពស្នើសុំ សម្តេច ឯកឧត្តម លោកជំទាវជាប្រធានក្រសួង ស្ថាប័នទាំងអស់ មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យបេក្ខជនកម្មសិក្សាការីមកពីបណ្តាក្រសួងស្ថាប័ន សាមី ដែលមានក្នុងសេចក្តីសម្រេចខាងលើ ដើម្បីទទួលបានសិទ្ធិចូលសិក្សាក្នុងវគ្គបណ្តុះបណ្តាលបន្ត ឆ្នាំ២០១៨ នៅសាលាភូមិន្ទរដ្ឋបាល ដោយដាក់កម្មសិក្សាការីនោះឲ្យស្ថិតក្នុងស្ថានភាពទំនេរពីមុខងារដោយរក្សាបៀវត្ស និងមុខតំណែងនៅដដែលក្នុងកំឡុងពេលសិក្សា។ ខ្ញុំសូមគោរពស្នើ សម្តេច ឯកឧត្តម លោកជំទាវ មេត្តាបញ្ជូនឈ្មោះបេក្ខជន ដែលក្រសួង ស្ថាប័ន សម្រេចអនុញ្ញាតឲ្យមានសិទ្ធិចូលសិក្សាក្នុងវគ្គបណ្តុះបណ្តាលបន្ត ឆ្នាំ២០១៨នេះមកសាលាភូមិន្ទរដ្ឋបាលផ្ទាល់ឲ្យបានមុនថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨នេះដោយក្តីអនុគ្រោះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សម្តេច ឯកឧត្តម លោកជំទាវ ប្រធានក្រសួង ស្ថាប័ន មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម សម្តេច ឯកឧត្តម លោកជំទាវ ប្រធានក្រសួង ស្ថាប័ន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានក្រុមប្រឹក្សាភិបាលសាលាភូមិន្ទរដ្ឋបាល**

**ពេជ្រ ប៊ុនធិន**

អាសយដ្ឋាន ៖ អគារលេខ ១៧ វិថីឧកញ៉ាញឹកតូឡុង (៥៦៦)
រាជធានីភ្នំពេញ , ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ 023 62 22 266
អ៊ីម៉ែល ៖ era.rsa@gmail.com គេហទំព័រ ៖ www.era.cambodia.gov.kh